# មេរៀនទី ១១៖ ពេត្រុស និងអនទ្រេជួបព្រះយេស៊ូវ

## យ៉ូហាន១៖៣៥-៤២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/cK56B_S7CnM

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/58JFa9pqny4

**គោលបំណង៖** ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៖៣៦** *"គាត់មើលទៅព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងទៅ ក៏ពោលថា នុ៎ះន៍ កូនចៀមនៃព្រះ។"*

**ចំរៀង** ( *យូធូបលីង* )៖
១.ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo
២.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
៣.ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«នាំកុមារទៅជួបព្រះយេស៊ូវ»**

**របៀបលេង៖**

១. ឲ្យកុមារណាម្នាក់(អាចជាកុមារដែលមានមាឌធំជាងគេក៏បាន) ស្ម័គ្រចិត្តធ្វើជាព្រះយេស៊ូវ ហើយឈរ នៅចុងម្ខាងនៃថ្នាក់រៀន
២. កុមារដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវឈរនៅចុងម្ខាងទៀត នៃថ្នាក់រៀន ហើយពួកគេអាចផ្លាស់ទី បាននៅពេលដែលគ្រូនិយាយ លេខណាមួយនៃម៉ោង។ ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា "៣ម៉ោង" នោះមានន័យថាពួកគេអាចដើរបាន៣ជំហាន។




ប្រសិនបើគ្រូនិយាយថា "៥ម៉ោង" នោះកុមារអាចដើរបាន៥ជំហាន។
៣. គោលបំណងនៃល្បែងនេះគឺដើម្បីចូលទៅជិតព្រះយេស៊ូវ ហើយប៉ះទ្រង់បាន។
៤. កុមារទី១ដែលអាចប៉ះព្រះយេស៊ូវបានមុនគេកុមារនោះជាអ្នកឈ្នះល្បែងនេះ។ ប៉ុន្តែយើងនឹងបន្តលេងល្បែងនេះ រហូតដល់កុមារគ្រប់គ្នាៗបានប៉ះព្រះយេស៊ូវ។
៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវតែខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីបានជួបព្រះយេស៊ូវពីព្រោះទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើងរាល់គ្នា។

**៤. ការណែនាំមេរៀន**

តើមានប្អូនៗណាខ្លះធ្លាប់ទន្ទឹងរង់ចាំម៉ាក់មកពីផ្សារ? ហើយចុះតើមានប្អូនៗណាខ្លះ ធ្លាប់ទន្ទឹងរង់ចាំប៉ាធ្វើដំណើរមកពីឆ្ងាយ? តើការរងចាំនរណាម្នាក់យូរឬរង់យូរណាស់មែនទេ? តើអ្នកនឹងមានអារម្មណ៍ដូចម្តេចនៅពេលដែលការទន្ទឹងរងចាំអ្វីមួយអស់ជាច្រើនឆ្នាំរបស់អ្នកបានមកដល់? នៅក្នុងព្រះគម្ពីរ មនុស្សបានធ្វើការរងចាំព្រះអង្គសង្គ្រោះក្នុងការយាងមក ដើម្បីរំដោះពួកគេពីលោកីយ៍នេះពីការរងទុក្ខ។ សាច់រឿងរបស់ព្រះគម្ពីររបស់យើងនៅថ្ងៃនេះគឺថា ទីបំផុតប្រជារាស្ត្របាន រកឃើញព្រះអង្គសង្គ្រោះហើយ គឺជាកូនចៀមនៃព្រះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងអំពីបុរស៣នាក់គឺ **យ៉ូហានបាទីស្ទ ពេត្រុស និងអនទ្រេ។** យ៉ូហាន-បាទីស្ទបានរៀបចំផ្លូវសម្រាប់ព្រះអង្គសង្គ្រោះ ដែលយើងអាចហៅបានថាកូនចៀមនៃព្រះ។ មនុស្សម្នាបានធ្វើការអធិស្ឋានដោយសង្ឃឹមក្នុងចិត្តថា ព្រះអង្គសង្គ្រោះនឹងយាងមកឆាប់ៗ។ ព្រះយេស៊ូវក៏បាន ឆ្លើយតបនឹងការអធិស្ឋានរបស់ពួកគេ។ បន្ទាប់មកថ្ងៃមួយ យ៉ូហានបាទីស្ទបានឃើញព្រះយេ-ស៊ូវដើរឆ្លងកាត់ទីនោះ រួចគាត់ក៏ពោលថា នោះគឺជាព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ! មនុស្សគ្រប់គ្នាមិនទាន់បានដឹងពីការនេះនោះទេ។

អនទ្រេនិងសិស្សរបស់លោកយ៉ូហានបាទីស្ទផ្សេងទៀតបានដើរតាមព្រះយេស៊ូវបន្ទាប់ពីលឺថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ។ បន្ទាប់ពីបានចំណាយពេលជាមួយព្រះយេស៊ូវមួយថ្ងៃ អនទ្រេបានដឹងថា គាត់បានរកឃើញព្រះមេស្ស៊ីហើយ គឺជាម្នាក់ដែលមនុស្សគ្រប់គ្នាកំពុងតែទន្ទឹងរងចាំ! ដោយមិនមានការស្ទាក់ស្ទើរអ្វីទាំងអស់ អនទ្រេគឺជាមនុស្សដំបូងគេដែលបានរត់ទៅរកបងប្រុសរបស់គាត់គឺ ស៊ីម៉ូនដើម្បីប្រាប់ថាគាត់បានរកឃើញព្រះមេស្ស៊ីហើយ។ ស៊ីម៉ូនបានឆ្លើយតបយ៉ាងលឿននឹងបានទៅជាមួយអនទ្រេ ដើម្បីជួបព្រះយេស៊ូវ ទីបំផុតគេក៏បានជួបកូនចៀមនៃព្រះ! ហើយនៅទីនោះព្រះយេស៊ូវបានប្តូរឈ្មោះ ស៊ីម៉ូនទៅជាពេត្រុស។

ការនិយាយថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ គឺមានន័យថា ព្រះយេស៊ូវបានជម្រះនូវអំពើបាបរបស់មនុស្ស ហើយបានថ្វាយកូនចៀមនៃព្រះ សម្រាប់ការអត់ទោសនៃអំពើបាបរបស់ពួកគេ។ ការបង្ហូរឈាមរបស់កូនចៀមគឺជាសញ្ញាបញ្ជាក់ពីការអត់ទោស។ ប៉ុន្តែនៅក្នុងច្បាប់នៃការថ្វាយកូនចៀម គឺត្រូវតែសម្លាប់កូនចៀមនោះ។ ព្រះយេស៊ូវគឺកូនចៀមនៃព្រះ ទ្រង់បានលះបង់ជីវិតសម្រាប់ពួកយើងរាល់គ្នា។ ព្រះយេស៊ូវបានលះបង់ជីវិតរបស់ទ្រង់ ដូច្នេះពួកយើងទាំងអស់គ្នាត្រូវបានសង្គ្រោះ។

អ្នកគឺពិតជាពិសេសខ្លាំងណាស់សម្រាប់ព្រះ។ ជាការពិតអ្នកគឺពិសេស ទើបព្រះបញ្ជូនព្រះរាជបុត្រាតែមួយរបស់ទ្រង់ គឺព្រះយេស៊ូវ មកទទួលទោសសម្រាប់អំពើបាបរបស់អ្នក។ ជំនួសឲ្យការទទួលទោស ព្រះយេស៊ូវចង់ឲ្យអ្នកសម្រាក និងទទួលបាននូវសន្តិភាពនៅពេលដែលអ្នកមករកទ្រង់។ ព្រះយេស៊ូវបានក្លាយទៅជាកូនចៀមនៃព្រះសម្រាប់អ្នក ពីព្រោះថាទ្រង់មិនមានបាបអ្វីសោះ។ អ្នកពិតជាពិសេសខ្លាំងណាស់ដែលព្រះយេស៊ូវសព្វព្រះទ័យក្នុងការសុគត់សម្រាប់អ្នក។ យើងសូមអរព្រះគុណព្រះអម្ចាស់ នៅថ្ងៃនេះ ដោយព្រោះកូនចៀមនៃព្រះទើបយើងរាល់គ្នាបានសង្គ្រោះ!

## ៦. សំនួរពិភាក្សា

១. តើយ៉ូហានបាទីស្ទបាននិយាយអ្វីនៅពេលដែលគាត់បានឃើញព្រះយេស៊ូវឆ្លងកាត់នោះ?
*(គាត់បាននិយាយថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ)*
២. តើអនទ្រេបានធ្វើដូចម្តេចនៅពេលដែលរកឃើញថាព្រះយេស៊ូវគឺជាព្រះមេស្ស៊ី ជាកូនចៀមនៃព្រះនោះ? *(គាត់បានរត់ចេញទៅរកបងប្រុសរបស់គាត់គឺ ពេត្រុស)*
៣. តើវាមានន័យដូចម្តេចនៅពេលដែលគេនិយាយថា ព្រះយេស៊ូវជាកូនចៀមនៃព្រះ?
*(វាមានន័យថា ព្រះយេស៊ូវបានជម្រះនូវអំពើបាបរបស់យើង)*
៤. តើអ្នកដឹងដោយរបៀបណាថា ព្រះយេស៊ូវគិតថាអ្នកជាមនុស្សពិសេសនោះ?
*(ព្រះយេស៊ូវបានសុគត់សម្រាប់យើង ប្រៀបដូចជាកូនចៀមនៃព្រះ ដើម្បីសង្គ្រោះពួកយើង)*

## ៧. ល្បែងកំសាន្ត «ស្វែងរកកូនចៀម»

សម្ភារៈដែលត្រូវការៈ  រូបភាព គោ តោ លា និងកូនចៀម (សូមមើលនៅទំព័រខាងក្រោម)

១. ព្រីនរូបភាពសត្វទាំង៤ហើយបិតវានៅលើជញ្ជាំងនៃថ្នាក់រៀនកន្លែង ផ្សេងៗគ្នា និងបិតវាពាក់កណ្តាលទៀតដើម្បីកុំឲ្យកុមារមើលឃើញរូប នៅ ខាងក្នុង។



២. ចាក់បទចម្រៀងហើយឲ្យកុមារទាំងអស់រាំជារង្វង់ នៅពេលដែលចម្រៀងឈប់កុមារត្រូវរត់ទៅប៉ះរូបភាពណាមួយក៏បាន ដែលពួកគេចង់បានហើយបើករូបនោះឲ្យពួកគេឃើញ។ ប្រសិនបើកុមារណាជ្រើសរើសបានរូបកូនចៀម នោះពួកគេនឹងឈ្នះល្បែងនេះ។

៣. គ្រូបន្តចាក់បទចម្រៀងហើយសិស្សទាំងអស់បន្តរាំទៀត។ នៅពេលដែលកុមារទាំងអស់កំពុងរវល់ក្នុង ការរាំ ជំនួយការគ្រូត្រូវជួយប្តូរទីតាំងរូបទាំងអស់នោះ។

៤. លេងល្បែងនេះ៥ដង។ ប្រសិនកុមារណាម្នាក់អាចចាប់ចំរូបរបស់កូនចៀមទាំង ៥ដង នោះគេនឹងទទួលបានកាដូ។

៥. តាមរយៈល្បែងនេះ សូមពន្យល់កុមារថា កូនចៀមតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ពីព្រោះថា ទ្រង់ជាកូនចៀមនៃព្រះ។ វាគឺពិតជាពិបាកសម្រាប់មនុស្សមួយចំនួនក្នុងការស្វែងរកព្រះយេស៊ូវ ប៉ុន្តែព្រះយេស៊ូវគឺតែងតែនៅជាមួយពួកយើងជានិច្ច ដូចជាកូនចៀមនៃព្រះ ដែលបានសុគត់សម្រាប់ពួកយើង។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន១៖៣៦** *"គាត់មើលទៅព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងទៅក៏ពោលថា នុ៎ះន៍កូនចៀមនៃព្រះ។"*

## ៩. ហត្ថកម្ម «ម៉ាស់មុខចៀម»

សម្ភារៈដែលត្រូវការៈ ចានក្រដាស កន្ត្រៃ ការបិទ ដុំសំឡី ដងឈើការ៉េម និងក្រដាសពណ៌ផ្កាឈូក

១. កាត់ផ្នែកកណ្តាលនៃចានក្រដាស

២. កាត់ត្រចៀកចៀមពីក្រដាសពណ៌ផ្កាឈូក



៣. បិតដុំសំឡីជាមួយរុំជុំវិញចានដែលបានកាត់រួច

៤. បិតត្រចៀកចៀមនៅផ្នែកខាងលើ

៥. បិតដងឈើការ៉េមនៅផ្នែកខាងក្រោម

៦. ឲ្យកុមារដាក់ម៉ាស់មុខចៀម ពីលើមុខរបស់ពួកគេហើយនិយាយថា
"កូនចៀមនៃព្រះបានសង្គ្រោះពួកយើង!"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវទ្រង់ស្គាល់ពួកយើង ល្អជាងពួកយើងស្គាល់ខ្លួនឯងទៅទៀត។ ព្រះអង្គអាចជួយយើងឲ្យស្គាល់ទ្រង់បានផងដែរ។ សូមអានព្រះគម្ពីរ **យ៉ូហាន ១៖៣៥-៤២** សារឡើងវិញ។ តើអ្នករៀនបានអ្វីពីព្រះយេស៊ូវនៅពេលដែលអ្នកជួបទ្រង់ជាលើកដំបូង? រៀនបានច្រើនណាស់ ត្រូវអត់? ប៉ុន្តែនៅមានរឿងជាច្រើនទៀតដែលយើងត្រូវតែដឹង។ នៅសប្តាហ៍នេះសូមទូលសុំព្រះ ឲ្យបង្រៀនអ្នកពីរឿងរ៉ាវថ្មីទៀតអំពីព្រះយេស៊ូវ។ បន្ទាប់មកសូមប្រាប់អ្នកផ្សេងទៀតពីអ្វីដែលអ្នកបានរៀន។ ប្រាកដណាស់ការចែកចាយរបស់អ្នកគឺពិតជាអាចជួយអ្នកដទៃបាន អ្នកជួយអ្នកដទៃបានប៉ុនណា នោះវាក៏អាចជួយដល់អ្នកបានប៉ុណ្ណោះដូចគ្នាដែរ។



---------------- បត់ទីនេះ ----------------



---------------- បត់ទីនេះ ----------------



------------------ បត់ទីនេះ ------------------



----------------- បត់ទីនេះ -----------------